គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

# ទស្សនាទាន
# ស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

ថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦

ដោយ៖ **ឯកឧត្តម លី ច័ន្ទតុលា**

**រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ក.ច.**

# មាតិកា

១ សេចក្តីផ្តើម

២ បញ្ហាប្រឈមក្នុងវិស័យពាណិជ្ជកម្ម និងតម្រូវការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

៣ ដំណើរការនៃការរៀបចំទស្សនាទានស្តីពីក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

៤ សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

៥ ផែនការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

# មាតិកា

១. សេចក្តីផ្តើម
២. បញ្ហាប្រឈមក្នុងវិស័យពាណិជ្ជកម្ម និងតម្រូវការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា
២.១. បញ្ហាប្រឈមក្នុងវិស័យពាណិជ្ជកម្ម
២.២. គោលបំណង
២.៣. លទ្ធផលរំពឹងទុក
៣. ដំណើរការនៃការរៀបចំទស្សនាទានស្តីពីក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា
៣.១. ក្របខ័ណ្ឌអភិបាលកិច្ច
៣.២. ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ
៣.៣. ទស្សនកិច្ចសិក្សា និងការសិក្សាពីឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ
៣.៤. ការសិក្សាស្រាវជ្រាវពីក្រមពាណិជ្ជកម្មពីប្រទេសអភិវឌ្ឍ និងប្រទេសដែលមានប្រព័ន្ធច្បាប់ស្រដៀងនឹងកម្ពុជា
៣.៥. ការសិក្សាពីវិធីសាស្ត្រនៃការរៀបចំក្រមរបស់កម្ពុជានិងអន្តរជាតិ
៤. សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា
៤.១. និយមន័យពាណិជ្ជកម្មក្នុងច្បាប់កម្ពុជា
៤.២. វិធានគ្រប់គ្រងលើវិស័យពាណិជ្ជកម្មដែលត្រូវដាក់ក្នុងក្រម
៤.៣.សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា
៥. ផែនការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

# ១. សេចក្តីផ្តើម

## ១. សេចក្តីផ្តើម

❖ស្របតាមមុំទី៤ នៃស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់(គ.ក.ច.) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

❖ដើម្បីជាទិសដៅការងារសម្រាប់ គ.ក.ច **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសឱ្យប្រើនូវ "**ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល**" កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ រួមជាមួយនឹងចក្ខុវិស័យ "**គ.ក.ច. ជានិម្មាបនករនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជានិងគុណតម្លៃសាកល**"។

❖ការដឹកនាំ និងសម្របសម្រួលចងក្រង និងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គឺជាយុទ្ធសាស្ត្រមួយនៅក្នុងផែនការកម្មវិធីការងាររយៈពេល ២០ឆ្នាំ របស់ គ.ក.ច ដែលមានការរៀបចំក្រមនីយកម្មគតិយុត្តតាមវិស័យជាកម្មវិធីគាំទ្រ។

❖**ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** បានផ្តល់អនុសាសន៍ផ្តួចផ្តើមគិតគូរលើការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជាក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។

## ចក្ខុវិស័យ

គ.ក.ច. ជានិម្មាបនករនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋ
ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា
និងគុណតម្លៃសាកល

**បេសកកម្ម ៖** ដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់កម្ពុជា ឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្តនិងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា

**ដំណាក់កាលទី១**
ពិនិត្យានុការូបនីយកម្មគតិយុត្ត

**ដំណាក់កាលទី២**
សុខដុមការូបនីយកម្មគតិយុត្ត

**ដំណាក់កាលទី៣**
ឯកសណ្ឋានូបនីយកម្ម
នៃប្រព័ន្ធច្បាប់

**ដំណាក់កាលទី៤**
បូរណភាពនៃប្រព័ន្ធច្បាប់
និងចីរភាពវប្បធម៌នីតិរដ្ឋ

**យុទ្ធសាស្ត្រគន្លឹះទី១៖**
ដឹកនាំ និង
សម្របសម្រួល
បងក្រង និង
ផ្សព្វផ្សាយច្បាប់
និងលិខិតបទដ្ឋាន
គតិយុត្ត

**យុទ្ធសាស្ត្រគន្លឹះទី២៖**
ដឹកនាំ និង
សម្របសម្រួល
រៀបចំក្របខ័ណ្ឌ
តាក់តែងច្បាប់
និងលិខិតបទដ្ឋាន
គតិយុត្ត

**យុទ្ធសាស្ត្រគន្លឹះទី៣៖**
ដឹកនាំ និង
សម្របសម្រួល
ពិនិត្យ និងវាយតម្លៃ
គុណភាពនិងប្រសិទ្ធភាព
នៃការ តាក់តែង និង
ការអនុវត្តច្បាប់និងលិខិត
បទដ្ឋានគតិយុត្ត

**យុទ្ធសាស្ត្រគន្លឹះទី៤៖**
ដឹកនាំ និង
សម្របសម្រួល
រៀបចំក្របខ័ណ្ឌ
ដោះស្រាយវិវាទ
គតិយុត្ត និងការពារ
នីត្យានុកូលភាព

**យន្តការគាំទ្រទី១៖**
គណៈកម្មការជំនាញទទួលបន្ទុក
តាមវិស័យ

**យន្តការគាំទ្រទី២៖**
ក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង
ស្ថាប័ន

**យន្តការគាំទ្រទី៣៖**
យន្តការស្ថាប័នអន្តរវិស័យ

**យុទ្ធសាស្ត្រគាំទ្រទី១៖**
រៀបចំផែនការសកម្មភាព
តាមដំណាក់កាលនីមួយៗ

**យុទ្ធសាស្ត្រគាំទ្រទី២៖**
រៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់
អនុវត្តយុទ្ធសាស្ត្រគន្លឹះទាំង៤

**យុទ្ធសាស្ត្រគាំទ្រទី៣៖**
រៀបចំប្រព័ន្ធឌីជីថលនូបនីយកម្ម
សម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះ
ទាំង៤ក្នុងយុគសម័យឌីជីថល

**យុទ្ធសាស្ត្រគាំទ្រទី៤៖**
រៀបចំផែនការអភិវឌ្ឍស្ថាប័ន
សម្រាប់ គ.ក.ច.

# ២. បញ្ហាប្រឈមក្នុងវិស័យពាណិជ្ជកម្ម និងតម្រូវការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

# ២.១. បញ្ហាប្រឈមក្នុងវិស័យពាណិជ្ជកម្ម

- អសង្គតិភាពរវាងច្បាប់នឹងច្បាប់
- អសង្គតិភាពរវាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់
- លិខិតបទដ្ឋានគតិយុត្តមានចំនួនច្រើន ហើយនៅដាច់ដោយឡែកពីគ្នា
- អនុលោមភាពច្បាប់ក្នុងវិស័យពាណិជ្ជកម្មមានច្រើនពេក (ការចុះបញ្ជី និងការសុំលិខិតអនុញ្ញាតឬអាជ្ញាប័ណ្ណ) ក៏ដូចជាភាពស្មុគស្មាញនៃនីតិវិធី
- វិវាទសមត្ថកិច្ចរវាងស្ថាប័នគ្រប់គ្រង
- ច្បាប់ខ្លះមិនអាចអនុវត្តបាន ឬហួសសម័យ (ច្បាប់ក្ស័យធន ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម)
- ការធ្វើឱ្យទំនើបកម្មនៃសេវាសាធារណៈ
- វិស័យខ្លះមិនទាន់មានវិធានគតិយុត្តិគ្រប់គ្រងច្បាស់លាស់ ជាពិសេសក្នុងវិស័យឌីជីថល
- ភាពលំបាក ក្នុងការស្វែងរកច្បាប់ ជាពិសេសលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់របស់ក្រសួង
- ទំនុកចិត្តលើប្រព័ន្ធតុលាការ និងយន្តការដោះស្រាយវិវាទពាណិជ្ជកម្ម
- បញ្ហាអភិបាលកិច្ច ។ល។

## ២.២. គោលបំណង

- ✓ លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម
- ✓ រក្សាបាននូវគុណតម្លៃកម្ពុជាក្នុងបរិបទសកលភាវូបនីយកម្ម ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមតក្កវិជ្ជាគតិយុត្តមួយច្បាស់លាស់
- ✓ កាត់បន្ថយភាពស្មុគស្មាញ និងលុបបំបាត់ផលប៉ះពាល់អវិជ្ជមានលើវិស័យពាណិជ្ជកម្ម
- ✓ ធានានូវស្តង់ដា ភាពទាន់ពេលវេលា គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តពីសំណាក់ធុរជន វិនិយោគិន និងជាពិសេសអ្នកទទួលផលចុងក្រោយ គឺប្រជាជនកម្ពុជា និងជាតិកម្ពុជាទាំងមូល។

# ២.៣. លទ្ធផលរំពឹងទុក

- ធានានូវសុខដុមភាវូបនីយកម្មនៃបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មកម្ពុជា ទាំងសង្គតិភាព និងនីត្យានុកូលភាព នៃការតាក់តែងការបកស្រាយ និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- មានគោលការណ៍ណែនាំច្បាស់លាស់ ងាយស្វែងរក ងាយអនុវត្តសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម ស្របតាមបរិការណ៍កម្ពុជា និងឧត្តមានុវត្តន៍អន្តរជាតិ
- បង្កើនទំនុកចិត្តក្នុងការវិនិយោគ និងអាជីវកម្ម តាមរយៈក្របខ័ណ្ឌច្បាប់មួយច្បាស់លាស់តាមតក្កវិជ្ជាគតិយុត្ត
- បង្កើនប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទពាណិជ្ជកម្ម
- ជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការវិនិយោគ និងអាជីវកម្មមួយដែលមានទំនុកចិត្ត និងស្តង់ដាជាតិកម្ពុជានិងអន្តរជាតិ។ល។

# ៣. ដំណើរការនៃការរៀបចំទស្សនាទានស្តីពីក្រមពាណិជ្ជកម្ម សម្រាប់កម្ពុជា

# ៣. ដំណើរការនៃការរៀបចំទស្សនាទានស្តីពីក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

៣.១. ក្របខ័ណ្ឌអភិបាលកិច្ច

៣.២. ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ

៣.៣. ទស្សនកិច្ចសិក្សា និងការសិក្សាពីឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ

៣.៤. ការសិក្សាស្រាវជ្រាវពីក្រមពាណិជ្ជកម្មពីប្រទេសអភិវឌ្ឍ និងប្រទេសដែលមានប្រព័ន្ធច្បាប់ស្រដៀងនឹងកម្ពុជា

៣.៥. ការសិក្សាពីវិធីសាស្ត្រនៃការរៀបចំក្រមរបស់កម្ពុជានិងអន្តរជាតិ

# ៣.១. ក្របខ័ណ្ឌអភិបាលកិច្ច

សេចក្តីសម្រេចលេខ១៤ សសរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៦ ស្តីពីការបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌទស្សនាទានស្តីពីក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៤ សសរ........

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងាររៀបចំក្របខ័ណ្ឌទស្សនាទានស្តីពីក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- យោងតាមសំណូមពរចាំបាច់នៃការងារ

១/៤

# ៣.២. ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ

**ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥៖** កិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំក្រមពាណិជ្ជកម្ម សម្រាប់កម្ពុជានៅខេត្តព្រះសីហនុ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ចន្ទី ពិសេដ្ឋ ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.**




**ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦៖** សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជានៅរាជធានីភ្នំពេញ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ចន្ទី ពិសេដ្ឋ ឧបនាយករដ្ឋមន្ត្រីប្រចាំការ។ ក្រោមប្រធានបទ៖** (១) ភាពចាំបាច់នៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា (២) វិធីសាស្ត្រនៃការរៀបចំក្រមពាណិជ្ជកម្ម និង (៣) មាតិកានៃក្រមពាណិជ្ជកម្ម។

# ៣.៣. ទស្សនកិច្ចសិក្សា និងការសិក្សាពីឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ

ថ្ងៃទី១៩ ដល់ ២៨ ខែមករា ឆ្នាំ២០២៦៖ ទស្សនកិច្ចសិក្សានៅប្រទេសបារាំងដើម្បីស្វែងយល់អំពីគោលការណ៍តាក់តែងក្រមពាណិជ្ជកម្មរបស់ប្រទេសបារាំង។

គណៈប្រតិភូបានធ្វើទស្សនកិច្ចនៅស្ថាប័នដូចជា៖

១. Université Paris 1 Panthéon-Sorbonne

២. គណៈកម្មាធិការជាន់ខ្ពស់ទទួលបន្ទុកក្រមនីយកម្ម (Commission Supérieure de Codification)

៣. សភាពាណិជ្ជកម្មអន្តរជាតិ (International Chamber of Commerce)

៤. សមាគម Henri Capitant









# ៣.៤. ការសិក្សាស្រាវជ្រាវពីក្រមពាណិជ្ជកម្មពីប្រទេសអភិវឌ្ឍ និងប្រទេស ដែលមានប្រព័ន្ធច្បាប់ស្រដៀងនឹងកម្ពុជា

| សហរដ្ឋអាមេរិក (UCC) | ប្រទេសបារាំង | ប្រទេសអាល្លឺម៉ង់ | ប្រទេសជប៉ុន |
|---|---|---|---|
| គន្ថីទី១ បទប្បញ្ញត្តិទូទៅ | គន្ថីទី១ បទប្បញ្ញត្តិទូទៅនៃពាណិជ្ជកម្ម | គន្ថីទី១ ទម្រង់សហគ្រាសពាណិជ្ជកម្ម | គន្ថីទី១ បទប្បញ្ញត្តិទូទៅ |
| គន្ថីទី២ ការលក់ទិញ | គន្ថីទី២ ទម្រង់សហគ្រាស | គន្ថីទី២ ក្រុមហ៊ុនសហកម្មសិទ្ធិ និងសហកម្មសិទ្ធិករកំបាំងមុខ | គន្ថីទី២ ក្រុមហ៊ុន |
| គន្ថីទី៣ ភតិសន្យា | គន្ថីទី៣ ទម្រង់នៃការលក់ទិញ និងផ្តាច់មុខ | គន្ថីទី៣ កំណត់ត្រាពាណិជ្ជកម្ម | គន្ថីទី៣ ប្រតិបត្តិការពាណិជ្ជកម្ម |
| គន្ថីទី៤ ឧបករណ៍ជួញដូរបាន | គន្ថីទី៤ សេរីភាពនៃតម្លៃលក់ និងការប្រកួតប្រជែង | គន្ថីទី៤ ប្រតិបត្តិការពាណិជ្ជកម្ម | គន្ថីទី៤ វិក័យបត្រ |
| គន្ថីទី៥ ប្រាក់បញ្ញើ | គន្ថីទី៥ ឧបការណ៍ជួញដូរបាន និងកិច្ចធានា | គន្ថីទី៥ ពាណិជ្ជកម្មតាមផ្លូវទឹក | គន្ថីទី៥ ច្បាប់ពាណិជ្ជកម្មតាមផ្លូវទឹក |
| គន្ថីទី៦ ការប្រាក់ | គន្ថីទី៦ ផលលំបាកក្នុងអាជីវកម្ម | | |
| គន្ថីទី៧ លិខិតឥណទាន | គន្ថីទី៧ តុលាការពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម | | |
| គន្ថីទី៨ ការលក់ដុំ | គន្ថីទី៨ ការគ្រប់គ្រងវិជ្ជាជីវៈវិស័យពាណិជ្ជកម្ម | | |
| គន្ថីទី៩ ឯកសារបញ្ជាក់កម្មសិទ្ធិ | គន្ថីទី៩ បទប្បញ្ញត្តិអនុវត្តលើទឹកដីក្រៅយុត្តាធិការ | | |
| គន្ថីទី១០ ការវិនិយោគមូលបត្រ | | | |
| គន្ថីទី១១ ប្រតិបត្តិការដែលមានកិច្ចធានា | | | |

# ការសិក្សាពីទំនាក់ទំនងពាណិជ្ជកម្ម

### ពាណិជ្ជករ និងពាណិជ្ជករ

( Business to Business )

អាជីវកម្មមួយ បង្កើននូវតម្លៃសម្រាប់អាជីវកម្មមួយ ឬច្រើនផ្សេងទៀត ដូចជាក្រុមហ៊ុន រោងចក្រ និង ស្ថាប័នរកប្រាក់ចំណេញ តាមរយៈការចុះកិច្ចសន្យាពាណិជ្ជកម្មជាដើម។

### ពាណិជ្ជករ និងរដ្ឋាភិបាល

( Business and Government )

ការធ្វើអាជីវកម្ម ជូនក្រសួង ស្ថាប័ន តាមរយៈការដេញថ្លៃ និងស្គង់ជារបស់រដ្ឋាភិបាលដែលបានកំណត់នៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

### ពាណិជ្ជករ និងអ្នកប្រើប្រាស់

( Business and consumer/end user )

ការធ្វើអាជីវកម្ម ជាមួយនឹងអ្នកប្រើប្រាស់ចុងក្រោយ ជារូបវន្តបុគ្គលដោយផ្ទាល់។

# ៣.៥.ការសិក្សាពីវិធីសាស្ត្រនៃការរៀបចំក្រមរបស់កម្ពុជានិងអន្តរជាតិ

វិធីសាស្ត្រនៃការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យតែមួយឱ្យស្ថិតក្នុងឯកសារតែមួយ មានសង្គតិភាព ឯកសណ្ឋាន និងសុខដុមនីយកម្មនៃបទប្បញ្ញត្តិគតិយុត្តជាធរមាន គឺមិនមានគោលការណ៍ណែនាំរួមជាស្តង់ដាអន្តរជាតិនោះទេ ពោលគឺអាស្រ័យទៅលើបរិបទរបស់ប្រទេស ការជះឥទ្ធិពលពីប្រព័ន្ធច្បាប់មួយមកលើច្បាប់នៃប្រទេសមួយផ្សេងទៀត ឬកើតចេញពីការសិក្សាជាបទពិសោធ ឬឧត្តមានុវត្តន៍ (Best practice) ពីគ្នាទៅវិញទៅមក។ កម្ពុជា ក៏មានបទពិសោធន៍ក្នុងការរៀបចំក្រមចំនួន៥ផងដែរ៖ ក្រមរដ្ឋប្បវេណី (២០០៧) ក្រមនីតិវិធីរដ្ឋប្បវេណី (២០០៦) ក្រមព្រហ្មទណ្ឌ (២០០៩) ក្រមនីតិវិធីព្រហ្មទណ្ឌ (២០០៧) និង ក្រមបរិស្ថាននិងធនធានធម្មជាតិ (២០២៣)។

**ជារួម វិធីសាស្ត្រនេះត្រូវបានមើលឃើញក្នុងរូបភាពចំនួន ៣ ដូចតទៅ៖**

### ១. ការប្រមូលផ្តុំ (Consolidation)

ការប្រមូលផ្តុំ គឺជាការប្រមូលចងក្រង និងប្រមូលផ្តុំបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយបង្ហាញនិង/ឬបញ្ចូលនូវលិខិតបទដ្ឋានគតិយុត្តដែលវិសោធនកម្ម និងលិខិតបទដ្ឋានគតិយុត្តនិរាករណ៍ ដោយពុំកែប្រែខ្លឹមសារឡើយ ដើម្បីធានាឱ្យបាននូវគោលការណ៍ពិនិត្យានុកូលភាព ពោលគឺដើម្បីសម្រួលដល់ការស្វែងរកនិងស្វែងយល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

### ២. ការចងក្រង (Compilation)

ការចងក្រងគឺជា ការប្រមូលផ្តុំអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តដាក់តាមលំដាប់លំដោយ ដែលរៀបចំតាមកម្មវត្ថុគតិយុត្តកាលប្បវត្តិ និងផ្ទៀងផ្ទាត់បទប្បញ្ញត្តិជាធរមាន ដោយអាចកែសម្រួលខ្លឹមសារ និងទម្រង់តិចតួច។ ការចងក្រងធ្វើឡើងដើម្បីធានាឱ្យបាននូវគោលការណ៍បូរណភាពនៃលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន និងសង្គតិភាពនៃការរៀបចំមាតិកា។

### ៣. ក្រម (Codification)

ក្រម គឺជាការប្រមូល ចងក្រង រៀបចំឡើងវិញនូវបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា ទាំងកម្រិតច្បាប់ និងកម្រិតឯកសារអនុវត្តប្រកបដោយរចនាសម្ព័ន្ធជាក់លាក់តាមតក្កវិជ្ជាគតិយុត្តមួយច្បាស់លាស់ និងក្នុងវិស័យជាក់លាក់ ដើម្បីសម្រេចបានឯកសារគតិយុត្តមួយដែលមានមាតិការួម និងមានអានុភាពគតិយុត្ត។

# គុណប្រយោជន៍និងគុណវិបត្តិ នៃការប្រមូលផ្ដុំ ការចងក្រង និងក្រម

| ប្រភេទ | គុណប្រយោជន៍ | គុណវិបត្តិ | ជម្រើស |
|---|---|---|---|
| **ការប្រមូលផ្ដុំ** | - វិធីសាស្ត្រសាមញ្ញ និងលឿន ដោយគ្រាន់តែប្រមូលច្បាប់និងលិខិតបទដ្ឋានទាំងអស់បញ្ចូលរួមគ្នា តាមរយៈកិច្ចសហការជាមួយ ក.ក.ច. នៅតាមក្រសួង ស្ថាប័ន<br>- ចំណាយធនធានតិច ទាំងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងពេលវេលា<br>- ជំនួយដល់អ្នកច្បាប់ និស្សិតច្បាប់ សាធារណៈជន ងាយស្រួលស្វែងរក និងសិក្សាពីច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធទាំងអស់។ | - ភាន់ច្រឡំលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលអសង្គតិភាព ឬអសុពលភាព<br>- ជាន់ ឬស្ទួន ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្រដៀងគ្នា<br>- គ្មានការរៀបចំជាលក្ខណៈប្រព័ន្ធបែបតក្កវិជ្ជាគតិយុត្ត<br>- ច្រើនទំព័រ ឬច្រើនអត្ថបទពិបាកស្វែងរក បោះពុម្ព និងផ្សព្វផ្សាយ | មិនគួរជ្រើសរើសវិធីសាស្ត្រនេះសម្រាប់ការប្រមូលច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រធានបទណាមួយឡើយ។ ប៉ុន្តែវិធីសាស្ត្រនេះអាចនឹងយកមកប្រើប្រាស់សម្រាប់ដំណាក់កាលដំបូងនៃការធ្វើក្រម។ |

# គុណប្រយោជន៍ និងគុណវិបត្តិនៃការប្រមូលផ្តុំ ការចងក្រង និងក្រម

| ប្រភេទ | គុណប្រយោជន៍ | គុណវិបត្តិ | ជម្រើស |
|---|---|---|---|
| **ការចងក្រង** | - ការចំណាយធនធាន ទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ក្នុងកម្រិតមធ្យម<br>- ក្លាយជាឧបករណ៍គន្លឹះដែលមានបទប្បញ្ញត្តិជាធរមានជួយដល់អ្នកច្បាប់ មន្ត្រីរាជការ និស្សិតច្បាប់ ធុរជន ក្នុងការស្វែងរក ស្វែងយល់ និងជាឯកសារយោងសម្រាប់ការបំពេញភារកិច្ច និងការសិក្សាពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានលើប្រធានបទដែលបានកំណត់<br>- ផ្តល់ភាពងាយស្រួលស្វែងរក និងចម្លងតាមមាតិកា ផ្នែក ឬចំណុចដែលចង់សិក្សាពាក់ព័ន្ធនឹងវិស័យ ឬការងាររបស់ខ្លួន<br>- ធានាបាននូវគោលការណ៍បូរណភាពនៃលិខិតបទដ្ឋានគតិយុត្តិ និងសង្គតិភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងសង្គតិភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន | - ត្រូវការធនធានមនុស្ស ជាអ្នកច្បាប់មានជំនាញខ្ពស់ និងការសម្របសម្រួលពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់ពីធរមាននៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត<br>- ត្រូវការអ្នកច្បាប់មានជំនាញខ្ពស់ ក្នុងវិស័យ ឬប្រធានបទជាក់លាក់ ដើម្បីរៀបចំមាតិកា<br>- ត្រូវការពេលវេលាពិនិត្យ បែងចែក និងសរសេរឡើងវិញក្នុងទម្រង់ជាអត្ថបទ<br>- កំហុសអក្ខរាវិរុទ្ធ និងឃ្លោងឃ្លាអាចខុសឆ្គងតិចតួចពីខ្លឹមសារដើម | ជាបទពិសោធ ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជ្រើសរើសវិធីសាស្ត្រ សម្រាប់ប្រមូលចងក្រងនូវច្បាប់ និងព្រះរាជក្រឹត្យសំខាន់ៗទាំងឡាយដែលស្ថិតនៅជាធរមាន ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយសាមញ្ញភាព បូរណភាព គុណភាព និងសោភណភាព សម្រាប់ជាគុណប្រយោជន៍ដល់ការស្វែងយល់និងការប្រតិបត្តិការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |

# គុណប្រយោជន៍ និងគុណវិបត្តិនៃការប្រមូលផ្តុំ ការចងក្រង ក្រម

| ប្រភេទ | គុណប្រយោជន៍ | គុណវិបត្តិ | ជម្រើស |
|---|---|---|---|
| ក្រម | - អនុញ្ញាតឱ្យមានការកែប្រែរចនាសម្ព័ន្ធនៃអត្ថបទគតិយុត្ត និរាករណ៍ ឬរៀបចំតាក់តែងបទប្បញ្ញត្តិឡើងវិញ ឬបំពេញបន្ថែមស្របតាមគោលការណ៍ទូទៅ គោលការណ៍គ្រឹះ និងតាមវិស័យជាក់លាក់<br>- ធានាបាននូវការគោរពគោលការណ៍ ឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត<br>- លុបបំបាត់ភាពដាច់ដោយដុំៗ និងភាពមិនច្បាស់លាស់នៃបទដ្ឋានគតិយុត្តក្នុងវិស័យតែមួយ និងធានាឯកសណ្ឋានគតិយុត្ត<br>- បញ្ជាក់បានច្បាស់នូវលិខិតបទប្បញ្ញត្តិស្រពេចស្រពិល និងធានាសុខដុមនីយកម្មនៃបទដ្ឋានគតិយុត្ត ដែលកំពុងស្ថិតនៅជាធរមាន<br>- កាត់បន្ថយអតិផរណានៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដោយគិតគូរទៅលើភាពធន់នៃច្បាប់<br>- បង្ហាញពីវិធាននិងនីតិវិធីនៃការអនុវត្ត និងការត្រួតពិនិត្យ<br>- ផ្តល់ភាពងាយស្រួលក្នុងការពិនិត្យ ប្រឹក្សា ស្វែងរក ស្វែងយល់អំពីវិធានគតិយុត្តក្នុងវិស័យជាក់លាក់។ | - ការចំណាយធនធាន ទាំងធនធានមនុស្ស ធនធានសម្ភារ និងធនធានហិរញ្ញវត្ថុ ក្នុងកម្រិតខ្ពស់ ដើម្បីប្រមូល ពិនិត្យ ផ្ទៀងផ្ទាត់<br>- ភាពស្មុគស្មាញ និងប្រើប្រាស់ពេលវេលាយូរសម្រាប់ការសិក្សារៀបចំ និងបំពេញនីតិវិធី<br>- ការកើតឡើងនៃវិវាទគតិយុត្តដែលទាមទារឱ្យមានការនិរាករណ៍ ឬធ្វើវិសោធនកម្ម<br>- តម្រូវការវិធីសាស្ត្រ និងធនធានសម្រាប់រៀបចំតម្រូវការនៃការធ្វើក្រម ទាំងទិដ្ឋភាពនយោបាយ ទិដ្ឋភាពគតិយុត្តនិងទិដ្ឋភាពបច្ចេកទេស<br>- ត្រូវការធនធានមនុស្ស ជាអ្នកច្បាប់មានជំនាញខ្ពស់ និងការសម្របសម្រួលពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូល និងកំណត់ពីធរមាននៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត<br>- ត្រូវការអ្នកច្បាប់មានជំនាញខ្ពស់ក្នុងវិស័យ ឬប្រធានបទជាក់លាក់ ដើម្បីវិភាគ វាយតម្លៃ រៀបចំ មាតិកា ខ្លឹមសារ ដែលអាចឈានដល់ការធ្វើនិរាករណ៍ផ្នែក ឬអត្ថបទច្បាប់ទាំងស្រុង និងអាចរៀបចំតាក់តែងថ្មី បំពេញបន្ថែម<br>- ទាមទារឱ្យមានការឯកភាព និងដឹកនាំការរៀបចំក្នុងកម្រិតនយោបាយ | ជាបទពិសោធកម្ពុជា បានរៀបចំក្រមចំនួន ៥ រួមមាន ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមបរិស្ថាននិងធនធានធម្មជាតិ។ ដោយឡែកវិធីសាស្ត្រនៃការរៀបចំក្រមនីមួយៗ ត្រូវបានរៀបចំឡើងតាមរយៈវិធីសាស្ត្រដោយឡែកពីគ្នា អាស្រ័យលើចរិតលក្ខណៈនៃវិស័យនីមួយៗ ជំនួយពីដៃគូអភិវឌ្ឍន៍និងបណ្តាប្រទេសជាមិត្ត។ |

# ៤. សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្ម

# ៤.១. និយមន័យពាណិជ្ជកម្មក្នុងច្បាប់កម្ពុជា

ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម**នៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់នូវនិយមន័យ ពាណិជ្ជករ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជា មុខរបរខ្លួនជាប្រចាំ។ ពាណិជ្ជកិច្ច ជាសកម្មភាពទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកចំណេញ។

**ច្បាប់នេះចាត់ទុកថាជាពាណិជ្ជកិច្ចរាល់សកម្មភាព ដែលមានចែងជាអាទិ៍ដូចខាងក្រោម៖**

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងក្នុងវិស័យអចលនទ្រព្យ
- រាល់សកម្មភាព នៃសហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកម្រៃជើងសារ សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និងសេវាដទៃទៀត
- ប្រតិបត្តិការនៃធនាគារប្តូររូបិយវត្ថុ
- ការផ្តល់សេវាអន្តរការ សេវាទីភ្នាក់ងារ ការិយាល័យសម្របសម្រួលកិច្ចការសេវាវប្បធម៌ និងការចាត់ចែងនូវទស្សនីយភាពជាសាធារណៈ
- ប្រតិបត្តិការនៃសហគ្រាសសំណង់ ការទិញ ឬការជួលនាវាដឹកជញ្ជូនក្នុងប្រទេស ឬក្រៅប្រទេស ការដឹកជញ្ជូន និងការផ្ញើបញ្ជូនតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស
- ការធានារ៉ាប់រងគ្រប់ប្រភេទ
- អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើ និង រ៉ែ ។

# ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មកម្ពុជា

❖ ក្នុងដំណើរនៃកិច្ចខិតខំប្រឹងប្រែងកែទម្រង់ក្នុងវិស័យពាណិជ្ជកម្មទាំងក្នុងនិងក្រៅស្រុក ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយសំខាន់ៗជាច្រើនក្នុងវិស័យពាណិជ្ជកម្ម ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់៖

- ✓ ច្បាប់ជាតិ ចំនួន ២១
- ✓ ច្បាប់អន្តរជាតិ ចំនួន ១៥
- ✓ អនុក្រឹត្យ ចំនួន ១២
- ✓ ប្រកាស ចំនួន ៣១
- ✓ គោលនយោបាយ ចំនួន ៣

❖ ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ក្រសួងពាណិជ្ជកម្មបានគ្រោងនូវផែនការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

- ✓ ច្បាប់ ចំនួន ៦
- ✓ សេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការអនុម័តកិច្ចព្រមព្រៀងចំនួន ៥ (បានឆ្លងរដ្ឋសភា)
- ✓ អនុក្រឹត្យ ចំនួន ២៥
- ✓ កិច្ចព្រមព្រៀង និងពិធីសារ ចំនួន ៩
- ✓ គោលនយោបាយ ចំនួន ១

# ៤.២. វិធានគ្រប់គ្រងលើវិស័យពាណិជ្ជកម្មដែលត្រូវដាក់ក្នុងក្រម

ការសោកល្បងកំណត់នូវវិធានគ្រប់គ្រងលើវិស័យពាណិជ្ជកម្មដែលត្រូវដាក់ក្នុងក្រមពាណិជ្ជកម្មកម្ពុជារួមមានវិធានដូចខាងក្រោម៖

- **បណ្តុំនៃវិធានដែលគ្របដណ្តប់លើវដ្តនៃសកម្មភាពពាណិជ្ជកម្ម៖** (១) ការចាប់ផ្តើមធ្វើពាណិជ្ជកម្ម (២) ប្រតិបត្តិការពាណិជ្ជកម្ម (៣) ការដោះស្រាយវិវាទ និង(៤) ការបិទសកម្មភាពពាណិជ្ជកម្ម
- **បណ្តុំនៃវិធានគតិយុត្តដែលគ្របដណ្តប់លើទំនាក់ទំនងពាណិជ្ជកម្ម៖** រួមមានទាំងអាជីវកម្មនិងអាជីវកម្ម និងអាជីវកម្មនិងអ្នកប្រើប្រាស់ចុងក្រោយ
- **បណ្តុំនៃវិធានដែលគ្របដណ្តប់រាល់សកម្មភាពស្វែងរកប្រាក់ចំណេញ៖** ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ច ដោយមិនគ្របដណ្តប់ដល់នីតិផ្សេងៗដែលជាសាខានៃនីតិសាធារណៈ (ដូចជា ពន្ធដារ គយ...) នោះទេ។

# ៤.៣.សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

| គន្ថីទី១ បទប្បញ្ញត្តិទូទៅ |
|---|
| មាតិកាទោល បទប្បញ្ញត្តិទូទៅ |
| **គន្ថីទី២ វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងសហគ្រាសពាណិជ្ជកម្ម** |
| មាតិកាទី១ វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម |
| មាតិកាទី២ សហគ្រាសពាណិជ្ជកម្ម |
| **គន្ថីទី៣ ម៉ាកនិងពាណិជ្ជនាម** |
| មាតិកាទី១ ម៉ាកនិងពាណិជ្ជនាម |
| មាតិកាទី២ ការប្រកួតប្រជែងមិនស្មោះត្រង់ |
| **គន្ថីទី៤ ប្រតិបត្តិការពាណិជ្ជកម្ម** |
| មាតិកាទី១ ទំនាក់ទំនងនៃការតំណាង |
| មាតិកាទី២ កិច្ចសន្យាពាណិជ្ជកម្ម |
| មាតិកាទី៣ ឧបករណ៍អាចជួញដូរបាន |
| មាតិកាទី៤ ប្រតិបត្តិការទូទាត់សងប្រាក់ |
| មាតិកាទី៥ ប្រតិបត្តិការដែលមានកិច្ចធានា |
| **គន្ថីទី៥ ការប្រកួតប្រជែង និងកិច្ចការពារអ្នកប្រើប្រាស់** |
| មាតិកាទី១ ការប្រកួតប្រជែង |
| មាតិកាទី២ កិច្ចការពារអ្នកប្រើប្រាស់ |

| គន្ថីទី៦ ស្ថានភាពលំបាកក្នុងពាណិជ្ជកម្ម |
|---|
| មាតិកាទី១ ការបង្ការ និងទប់ស្កាត់ការលំបាករបស់សហគ្រាស |
| មាតិកាទី២ នីតិវិធីការពារ |
| មាតិកាទី៣ ការស្តារអាជីវកម្មតាមផ្លូវតុលាការ |
| មាតិកាទី៤ ការរំលាយសហគ្រាសតាមផ្លូវតុលាការ |
| មាតិកាទី៥ ការបិទសហគ្រាស |
| **គន្ថីទី៧ ការដោះស្រាយវិវាទ** |
| មាតិកាទី១ វិវាទពាណិជ្ជកម្ម |
| មាតិកាទី២ វិវាទជាមួយអ្នកប្រើប្រាស់ |
| **គន្ថីទី៨ ទោសប្បញ្ញត្តិ** |
| មាតិកាទី១ បទប្បញ្ញត្តិទូទៅ |
| មាតិកាទី២ បទល្មើសក្នុងវិស័យពាណិជ្ជកម្ម |
| **គន្ថីទី៩ អន្តរប្បញ្ញត្តិ** |
| **គន្ថីទី១០ អវសានប្បញ្ញត្តិ** |

# ៥. ផែនការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

# ៥. ផែនការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

| ល.រ | សកម្មភាព | រយៈពេល |
|---|---|---|
| **ដំណាក់កាលទី១. ការរៀបចំទស្សនាទានក្រមពាណិជ្ជកម្ម** | | |
| ១ | កិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា | រយៈពេល ៨ខែ (ខែវិច្ឆិកា ឆ្នាំ២០២៥ ដល់ ខែមិថុនា ឆ្នាំ២០២៦) |
| ២ | បង្កើតក្រុមការងាររៀបចំទស្សនាទានស្ដីពីក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា | |
| ៣ | ការសិក្សាស្រាវជ្រាវឧត្តមានុវត្តន៍អន្តរជាតិពាក់ព័ន្ធនឹងវិធីសាស្ត្រតាក់តែងក្រម | |
| ៤ | ទស្សនកិច្ចសិក្សាទៅប្រទេសបារាំង | |
| ៥ | សិក្ខាសាលាស្ដីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា | |
| **ដំណាក់កាលទី២. ការរៀបចំក្រមពាណិជ្ជកម្ម** | | |
| ១ | បង្កើតក្រុមការងារកម្រិតរាជរដ្ឋាភិបាលរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា | ៣៦ខែ |
| ២ | ដំណើរនៃការរៀបចំសេចក្ដីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា | |

# ៥. ផែនការនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

| ដំណាក់កាលទី៣. ការអនុម័ត និងការផ្សព្វផ្សាយក្រមពាណិជ្ជកម្ម | | |
|---|---|---|
| ១ | សេចក្តីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជាដាក់ឆ្លងក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រីដោយក្រុមការងារអន្តរក្រសួងនៃរាជរដ្ឋាភិបាល | ១២ខែ |
| ២ | សេចក្តីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជាដាក់ជូនគណៈកម្មការអចិន្ត្រៃយ៍ និង គណៈកម្មការជំនាញនៃរដ្ឋសភា | |
| ៣ | សេចក្តីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជាដាក់ជូនព្រឹទ្ធសភា | |
| ៤ | សេចក្តីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជាដាក់ថ្វាយព្រះមហាក្សត្រ | |
| ៥ | ការផ្សព្វផ្សាយក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា | |

# គុណតម្លៃស្នូល របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

ទី១

## នីតិរដ្ឋ និងការការពារផលប្រយោជន៍សាធារណៈ

ការប្រកាន់ខ្ជាប់នូវគោលការណ៍នីតិរដ្ឋនិងការការពារផលប្រយោជន៍សាធារណៈត្រូវស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលសំដៅចូលរួមគាំទ្រការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយបរិយាបន្ននិងចីរភាព។

ទី២

## សាមគ្គីភាព និងបរិយាបន្ន

ការចូលរួម ការគាំទ្រ ការចែករំលែក និងការសហការបំពេញការងារជាក្រុមក្នុងស្មារតីម្ចាស់ការ សាមគ្គីភាព និងការទទួលខុសត្រូវខ្ពស់ គឺជាមូលដ្ឋានដ៏រឹងមាំដើម្បីសម្រេចបានលទ្ធផលល្អប្រសើរ។

ទី៣

## គុណាធិបតេយ្យ

ការជ្រើសរើស ការចាក់តាំង ការតែងតាំង ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការផ្តល់គ្រឿងឥស្សរិយយស ការលើកទឹកចិត្តនិងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀត ត្រូវផ្អែកលើសមត្ថភាព និងគុណវុឌ្ឍិរបស់មន្ត្រី។

ទី៤

## វិជ្ជាជីវៈ និងក្រមសីលធម៌

មន្ត្រីគ្រប់រូបចាំបាច់មានវិជ្ជាជីវៈ និងត្រូវប្រតិបត្តិក្រមសីមលធម៌មន្ត្រីសាធារណៈ រួមមាន៖ ការគោរពពេលវេលា ឋានានុក្រម ការចាត់តាំង និងវិន័យការងារ ព្រមទាំងការរក្សាសីលធម៌ សុចរិតភាព ភក្ដីភាព ឥស្សរភាព អព្យាក្រឹតភាព និងអាទិភាព សំដៅធានាឱ្យបាននូវគុណតម្លៃ កិត្តិយស និងសេចក្ដីថ្លៃថ្នូរ។

# សូមគោរពអរគុណ